ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សៀវភៅណែនាំស្តីពី
# បច្ចេកទេសចិញ្ចឹមកន្ធាយ







រៀបចំដោយ:
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២០២០



អាសយដ្ឋាន : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០១២ ៩៨ ៨៣ ៣៧
: ០៩៩ ៨៤ ៤៦ ៦៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/Department of Agricultural Extension

គេហទំព័រ : http://www.khmeragri.info



ក្រុមការងារចងក្រង កូនសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមកន្ធាយ សូមការអធ្យាស្រ័យពីប្រិយមិត្តអ្នកអានផងដែរ បើសិនជាការបោះពុម្ពផ្សាយកូនសៀវភៅ ជាលើកទី១នេះនៅមានការខ្វះចន្លោះ ផ្នែកបច្ចេកទេស រូបភាព និងអក្ខរាវិរុទ្ធ រាល់ការខ្វះខាតទាំងនេះ ក្រុមការងារយើងខ្ញុំសង្ឃឹមថា នឹងទទួលបាននូវការជួយកែលម្អ បំពេញបន្ថែមពីសំណាក់ប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន រាល់ការកែលម្អទាំងអស់នោះ ក្រុមការងារយើងខ្ញុំ នឹងយកទៅចងក្រងសម្រាប់ការបោះពុម្ពផ្សាយជាលើកទី២បន្តទៀតៗ។ សូមអរគុណ!





# សៀវភៅណែនាំ

## ស្តីពី

## បច្ចេកទេសចិញ្ចឹមកន្ធាយ


### រៀបចំដោយ

### នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សហការជាមួយ

### នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធិដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីបច្ចេកទេសចិញ្ចឹមកន្ធាយ

## I. ទីប្រឹក្សាផ្តល់យោបល់:

១. ឯកឧត្តម **អេង ជាសាន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## III. ក្រុមបកប្រែ:

១. លោក **យុន សុផាន** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. លោក **ព្រំ វិសិដ្ឋ** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **រស់ គន្ធី** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

២. លោក **អ៊ុច ឡង់** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

៣. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។







# មាតិកា

ទំព័រ


I. **សេចក្តីផ្តើម** ........ ០១

II. **ស្ថានភាពទូទៅ** ........ ០៣

III. **លក្ខណៈជីវសាស្ត្រ** ........ ០៥

១. ចរិកស៊ីចំណី ........ ០៧

២. ការលូតលាស់ ........ ០៧

៣. ការបន្តពូជ ........ ០៨

IV. **បច្ចេកទេសចិញ្ចឹមកន្ធាយ** ........ ០៩

១. ប្រភពទឹកសម្រាប់ចិញ្ចឹមកន្ធាយ ........ ០៩

២. ការជ្រើសរើសកូនពូជដាក់ចិញ្ចឹម ........ ០៩

៣. ការរៀបចំស្រះចិញ្ចឹមកន្ធាយ ........ ១០

៤. ដង់ស៊ីតេកូនកន្ធាយដាក់ចិញ្ចឹម ........ ១២

៥. ចំណី និងការផ្តល់ចំណី ........ ១៣

៦. ការគ្រប់គ្រងស្រះ ........ ១៦

៧. ជំងឺ និងការបង្ការជំងឺ ........ ១៨

៨.ការប្រមូលផល ........ ២២






# បច្ចេកទេសចិញ្ចឹមកន្ធាយក្នុងស្រះ

## I. សេចក្តីផ្តើម

កន្ធាយ គឺជាប្រភេទសត្វឈាមត្រជាក់ ស្ថិតក្នុងអំបូរ Trionychidae ដែលបច្ចុប្បន្ននេះ រួមមានបីប្រភេទសំខាន់ បាន និងកំពុងចិញ្ចឹមក្នុងប្រទេសកម្ពុជាយើងគឺ កន្ធាយផ្កាមានឈ្មោះវិទ្យាសាស្ត្រ Tryonyx sinensis កន្ធាយបន្លា មានឈ្មោះវិទ្យាសាស្ត្រ Tryonyx steinachderi និងកន្ធាយស្មៅ មានឈ្មោះវិទ្យាសាស្ត្រ Tryonyx cartilagineus។

ការចិញ្ចឹមកន្ធាយ បាន និងកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់បងប្អូនប្រជាកសិករ និងវារីវប្បករកម្ពុជាយើងនៅតាមបណ្តាខេត្តមួយចំនួននៅភាគខាងជើងប្រទេស ជាពិសេស នៅក្នុងខេត្តសៀមរាបដែលបានចាប់ដំណើរការចិញ្ចឹមចាប់តាំងពីឆ្នាំ២០០៨មកម្លេះ ក្រោមការដឹកនាំ ផ្តល់បច្ចេកទេសអនុវត្ត ធ្វើដោយផ្ទាល់ពីសំណាក់មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល ។ សកម្មភាពចិញ្ចឹមកន្ធាយតាមបែបជាលក្ខណៈគ្រួសារនេះ បន្ទាប់ពីបានទទួលជោគជ័យលទ្ធផលល្អជាបណ្តើរៗកន្លងមក ពោលគឺចាប់ឆ្នាំ២០០៨ កន្លងមកនេះ ក៏បានធ្វើឱ្យកសិករផ្សេងៗទៀតនៅក្នុងតំបន់ មូលដ្ឋាន ខេត្តសៀមរាប ជាពិសេស វារីវប្បករវ័យក្មេងៗជំនាន់ក្រោយជាច្រើនបានចាប់អារម្មណ៍ចិញ្ចឹមបន្តមកដល់ឆ្នាំ២០២០ នាពេលបច្ចុប្បន្ននេះ។ ការចិញ្ចឹមកន្ធាយ នាពេលបច្ចុប្បន្ននេះ បានកំពុងក្លាយជាមុខរបរថ្មីមួយដ៏សំខាន់ តាមបែបពាណិជ្ជកម្ម របស់វារីវប្បករវ័យក្មេងមួយចំនួននៅខេត្តសៀមរាប ក្នុងប្រទេសកម្ពុជាយើង បើប្រៀបធៀបទៅនឹងមុខរបរចិញ្ចឹមត្រី ចិញ្ចឹមកង្កែប ឬមុខរបរកសិកម្មផ្សេងទៀត។ របរចិញ្ចឹមកន្ធាយនេះ ត្រូវបានគេអះអាងថា មានតម្រូវការលើទីផ្សារខ្ពស់ ដោយសារតែវាជាម្ហូបអាហារ ពេញនិយមនៅតាមបណ្តាភោជនីយដ្ឋាន ឬអាហារដ្ឋានជាច្រើននៅក្នុងខេត្តសៀមរាប ក៏ដូចជានៅតាមបណ្តាខេត្តផ្សេងៗទៀតដែលស្ថិតក្នុងតំបន់ទេសចរណ៍។





*កសិករ ប៉ៃ សំអូន នៅភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប កំពង់ជោគជ័យលើមុខរបរចិញ្ចឹមកន្ធាយ*

ដោយមើលឃើញថា កន្ធាយ ជាវារិសត្វមួយប្រភេទ មានសក្តានុពលខ្លាំងនៅក្នុងវិស័យវារីវប្បកម្ម បន្ទាប់ពីបង្កង ហើយវាក៏មានតម្លៃសេដ្ឋកិច្ចខ្ពស់ផងដែរនៅលើទីផ្សារ ទាំងនៅក្នុងស្រុក តាមតំបន់មូលដ្ឋាននានានៃប្រទេសកម្ពុជា និងសម្រាប់ការនាំចេញទៅក្រៅប្រទេសនាពេលអនាគត នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល ក្រោមការចង្អុលបង្ហាញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំចងក្រងកូនសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមកន្ធាយនេះឡើង ក្នុងគោលបំណង លើកទឹកចិត្តឱ្យមានការចិញ្ចឹមកន្ធាយក្នុងស្រុក ឱ្យបានកាន់តែច្រើនបន្ថែមទៀតខណៈពេលដែលបច្ចុប្បន្ននេះការចិញ្ចឹមនៅមានចំនួនតិចតួចនៅឡើយ ក៏ដូចជាការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹម នៅមានកម្រិត។

ការចូលរួមរបស់ផ្នែកឯកជន លើការវិនិយោគវិស័យជលផល ពិសេសផ្នែកវារីវប្បកម្ម គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារាជរដ្ឋាភិបាលដើម្បីបង្កើនបរិមាណផ្គត់ផ្គង់ក្នុងស្រុក និងធានាបានទាំងបរិមាណ គុណភាព និងតម្លៃ ឆ្លើយតបតាមសេចក្តីត្រូវការទីផ្សារដែលកំពុងមានតម្រូវការកាន់តែខ្ពស់ពីមួយថ្ងៃទៅមួយថ្ងៃ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានជំរុញឱ្យផ្នែក

ឯកជន ខិតខំបង្កើនការចិញ្ចឹមកន្ធាយឱ្យបានកាន់តែច្រើនថែមទៀត ខណៈកន្ធាយគឺជាវារិសត្វមួយប្រភេទ ងាយស្រួលចិញ្ចឹមទាំងបែបលក្ខណៈគ្រួសារ មធ្យម និងឧស្សាហ៍កម្ម ឬពាណិជ្ជកម្ម ព្រមទាំងមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅលើទីផ្សារ ទាំងក្នុងនិងក្រៅប្រទេស។ ការពង្រីកផ្ទៃដីចិញ្ចឹមកន្ធាយនាពេលអនាគត នឹងអាចចូលរួមចំណែកក្នុងការបង្កើតឱកាសការងារថ្មីៗសម្រាប់ប្រជាកសិករ បង្កើនប្រាក់ចំណូល និងកាត់បន្ថយការយកប្រាក់ទៅចំណាយលើផលិតផលនាំចូលពីប្រទេសជិតខាង។ នៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ ក្នុង១ថ្ងៃមានតម្រូវការកន្ធាយមិនក្រោម ៤ តោននោះទេ ក្នុងនោះប្រហែល ៦០% ត្រូវបាននាំចូលមកពីប្រទេសជិតខាង។





*សត្វកន្ធាយកំពុងមានទីផ្សារល្អក្នុងពេលបច្ចុប្បន្ន*

បច្ចុប្បន្ននេះដែរ កន្ធាយដែលបានយកទៅលក់នៅលើទីផ្សារ គឺមានអាយុ ១ ឆ្នាំ មានទម្ងន់ ១ គីឡូក្រាម និងមានតម្លៃ ១០ ដុល្លារ សម្រាប់កន្ធាយតូចៗ មានទម្ងន់ក្រោម ១គីឡូក្រាម អាចមានតម្លៃចន្លោះពី ៧-៨ដុល្លារ។

## II. ស្ថានភាពទូទៅ

កន្ធាយផ្កា មានឈ្មោះវិទ្យាសាស្ត្រ Tryonyx sinensis ជាប្រភេទកន្ធាយដែល

ត្រូវបានគេនិយម ចូលចិត្តចិញ្ចឹមយ៉ាងទូលំទូលាយបំផុតក្នុងប្រទេសចិន និងបណ្តាប្រទេសមួយចំនួនផ្សេងៗទៀត នៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ដូចជាៈ ប្រទេសថៃឡង់ដ៍ និងវៀតណាម ព្រមទាំងនៅក្នុងបណ្តាប្រទេសអាស៊ីផ្សេងទៀតដូចជាៈ ជប៉ុន និងកោះតៃវ៉ាន់ជាដើម។ល។ កន្ធាយប្រភេទនេះ ត្រូវបានគេមានការចាប់អារម្មណ៍ជាខ្លាំង និងយកទៅចិញ្ចឹមតាមបែបជាលក្ខណៈពាណិជ្ជកម្ម ដោយសារតែវាមានកំលាំងបន្តពូជខ្លាំង ងាយស្រួលបង្កាត់ ភ្ញាស់ អាចផលិតកូនពូជបានច្រើន និងមានតម្រូវការច្រើន និងមានតម្លៃសេដ្ឋកិច្ចខ្ពស់លើទីផ្សារ ។

ដោយឡែក នៅក្នុងប្រទេសចិន ក៏មានប្រជាកសិករជាច្រើន បានចាប់អារម្មណ៍នៅក្នុងការចិញ្ចឹមកន្ធាយនេះផងដែរ នៅតាមបណ្តាខេត្តជាច្រើន រួមមានដូចជាៈ ខេត្តលីយ៉ាននីង សានស៊ី អានហ្វ៊ួយ ហ្សេជាំង ក្វាងទុង។ល។ ក្រៅពីនេះ មានប្រទេសជាច្រើនផ្សេងទៀត ក៏មានប្រជាកសិករនិយមចូលចិត្តចិញ្ចឹមកន្ធាយនេះផងដែរ ដូចជាៈ កោះតៃវ៉ាន់ ភាគខាងត្បូងនៃចុងបូព៌ាប្រទេសរុស្ស៊ី កូរ៉េ កោះ Bonin ឥណ្ឌូណេស៊ី (ទីម័រ) និងជប៉ុនជាដើម ។ល។ បទពិសោធន៍ បច្ចេកទេសចិញ្ចឹមកន្ធាយទាំងនេះក៏ត្រូវបានគេផ្សព្វផ្សាយបន្ត ទៅកាន់ភាគខាងលិចនៃប្រទេសម៉ាឡេស៊ី និងសហរដ្ឋអាមេរិកផងដែរ ហើយប្រទេសម៉ាឡេស៊ី បានធ្វើការនាំចេញបានចំនួន៨២៨តោន លើប្រភេទផ្សេងគ្នាកាលពីឆ្នាំ១៩៩៨។

ក្រៅពីនេះ មិនមានទិន្នន័យនាំចេញកន្ធាយជាក់លាក់នោះទេ ពីបណ្តាប្រទេសមួយចំនួនដូចជាៈ កម្ពុជា ឡាវ វៀតណាម និងមីយ៉ាន់ម៉ា។

យើងដឹងហើយថា បើទោះជាកន្ធាយ ជាប្រភេទពូជដែលត្រូវបានគេថែរក្សាការពារ និងអភិរក្សយ៉ាងណាក៏ដោយ តែកន្ធាយចិញ្ចឹមតាមកសិដ្ឋាននានា ដែលមានលិខិត និងច្បាប់អនុញ្ញាតិត្រឹមត្រូវគឺយើងអាចធ្វើការលក់ ឬជួញដូរបាន ជាលក្ខណៈពាណិជ្ជកម្មនៅលើទីផ្សារ ព្រោះថា ការចិញ្ចឹមកន្ធាយ អាចជួយបាន នៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករនៅតាមជនបទ ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនៅតំបន់អាស៊ី។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីលើកទឹកចិត្តឱ្យមានការចិញ្ចឹម ការបង្កាត់

ជ្រើសរើសពូជល្អៗសម្រាប់ចិញ្ចឹម  គឺជាការចាំបាច់បំផុតក្នុងការធ្វើឱ្យមានភាពធន់ទ្រាំនឹងជំងឺ ក៏ដូចជាក្នុងលក្ខខ័ណ្ឌស្រះ កសិដ្ឋានចិញ្ចឹម ឱ្យមានការលូតលាស់ ធំធាត់លឿន ដូច្នេះចាំបាច់ត្រូវមានការអភិវឌ្ឍន៍បច្ចេកទេសចិញ្ចឹមឱ្យកាន់តែល្អប្រសើរឡើង។




ប្រភេទសត្វកន្ធាយកំពុងចិញ្ចឹមក្នុងប្រទេសកម្ពុជា

## III. លក្ខណៈជីវសាស្ត្រ

យើងបានដឹងហើយថា កន្ធាយ គឺជាប្រភេទសត្វឈាមត្រជាក់ ស្ថិតក្នុងអំបូរ Trionychidae ដែលបច្ចុប្បន្ននេះ រួមមានបីប្រភេទសំខាន់ បាន និងកំពុងចិញ្ចឹមក្នុងប្រទេសកម្ពុជាយើងគឺកន្ធាយផ្កាមានឈ្មោះវិទ្យាសាស្ត្រ Tryonyx sinensis  កន្ធាយបន្លា មានឈ្មោះវិទ្យាសាស្ត្រ  Tryonyx steinachderi  និងកន្ធាយស្មៅ មានឈ្មោះវិទ្យាសាស្ត្រ Tryonyx cartilagineus។




កន្ធាយផ្កា (Tryonyx sinensis)




កន្ធាយបន្លា ( Trionyx Steinachderi)




កន្ធាយស្មៅ (Trionix Tryonyx cartilagineus)

ជាទូទៅ កន្ធាយចូលចិត្តរស់នៅក្នុងទឹក ជាងការរស់នៅលើគោក។ ប៉ុន្តែ ការរស់នៅលើគោក ក៏ជាតម្រូវការចាំបាច់ផងដែរ ព្រោះថា កន្ធាយធ្វើការដកដង្ហើមសំខាន់ គឺតាមប្រព័ន្ធផ្លូវដកដង្ហើមតាមសួតដែលយើងតែងតែសង្កេតឃើញថា វាងើបក្បាលនៅលើផ្ទៃទឹកយូរៗម្តង នោះហើយជាការដកដង្ហើមរបស់វាតាមសួតក្នុងបរិយាកាស។ តែយ៉ាងណាក៏វាត្រូវការដកដង្ហើម ស្រូបយកបរិមាណអុកស៊ីហ្សែនតាមរយៈស្បែកផងដែរនៅពេលវារស់នៅក្នុងទឹក ជាពិសេស នៅក្នុងរដូវអាកាសធាតុត្រជាក់ វាតែងតែចូលចិត្ត ទៅរស់នៅក្នុងភក់ក្រោមស្រទាប់ទឹក ដូចជាៈ នៅបាតទន្លេ ស្ទឹង បឹងបួរ និងតាមវាលស្រែ។ល។ កន្ធាយ មានចំណុច លក្ខណៈជីវសាស្ត្រសំខាន់ៗមួយចំនួនផ្សេងទៀតដែលកសិករ និងវារីវប្បករត្រូវយល់ដឹង ដូចខាងក្រោម៖

## ១. ចរិកស៊ីចំណី

កន្ធាយ ជាប្រភេទសត្វស៊ីសាច់ជាអាហារសំខាន់។ ជាធម្មតា ពេលនៅតូច បន្ទាប់ពីញាស់បានមួយថ្ងៃ វាចាប់ផ្តើមចេះរកចំណីស៊ីខាងក្រៅបានដោយខ្លួនឯង។ នៅក្នុងធម្មជាតិ ចំណីសំខាន់ៗរបស់វារួមមាន ដូចជាៈ ពពួកសត្វល្អិតប្លង់តុង ជន្លេនទឹក ឬជន្លេនក្រហម កូនត្រីល្អិតៗ កំពឹស ក្តាម ខ្យង។ល។ តែករណី លក្ខខ័ណ្ឌចិញ្ចឹមក្នុងស្រះវិញ កន្ធាយអាចស៊ីបាននូវចំណីផ្សំពីសមាសធាតុសាច់ផ្សេងៗ ដូចជាៈកាកសំណល់ត្រី មាន់ ទា ។ល។ ដែលមានតម្លៃថោក និងប្រភេទចំណីគ្រាប់ ផលិតចេញពីរោងចក្រ។



កូនកន្ធាយកំពុងស៊ីចំណីផ្សំ



ចំណីផលិតចេញពីរោងចក្រ

## ២. ការលូតលាស់

ការលូតលាស់របស់កន្ធាយ អាស្រ័យជាសំខាន់លើ ប្រភេទកន្ធាយនីមួយៗផ្សេងគ្នា បច្ចេកទេសចិញ្ចឹមផ្សេងៗគ្នា និងល័ក្ខខ័ណ្ឌបរិស្ថានចិញ្ចឹម។ ករណី ចិញ្ចឹមកូនពូជទំហំចន្លោះពី១០០-២០០ក្រាម/ក្បាល ក្នុងរយៈពេលពី៦-៨ខែ អាចមានទម្ងន់ចន្លោះពី ០.៨-១.០គ.ក្រ/ក្បាល នៅក្នុងល័ក្ខខ័ណ្ឌបរិស្ថានសីតុណ្ហភាពប្រទេសកម្ពុជា តែអាចមានទម្ងន់ចន្លោះពី ០.៥-០.៨គ.ក្រ/ក្បាល ប៉ុណ្ណោះ ករណីក្នុងល័ក្ខខ័ណ្ឌបរិស្ថានសីតុណ្ហភាពទាប នៅភូមិភាគខាងជើងនៃប្រទេសវៀតណាម និងប្រទេសចិន។ កម្រិតសីតុណ្ហភាពទឹកសមស្របបំផុតសម្រាប់ការលូតលាស់ ក៏ដូចជាការបន្តពូជ ពងកូនរបស់កន្ធាយ មានកម្រិតចន្លោះពី ២៥-៣០អង្សាសេ តែករណីក្រោម ២៥

អង្សាសេ ឬ លើសពី ៣២ អង្សាសេ អាចមានបញ្ហា ដូចជាបណ្តាលឱ្យកន្ធាយស៊ីចំណីតិច ឬមិនស៊ីចំណីតែម្តង និងមានការលូតលាស់ ធំធាត់យឺត។

### ៣. ការបន្តពូជ

ជាទូទៅ កន្ធាយមានទម្ងន់ចាប់ពី០.៥-២គ.ក្រ/ក្បាល ឡើងទៅ និងមានអាយុ ២ឆ្នាំ ទើបអាចធ្វើការបន្តពូជបាន ហើយតែងតែធ្វើការបន្តពូជនៅក្នុងរដូវវស្សា មានភ្លៀងធ្លាក់ ។ កន្ធាយ ជាប្រភេទសត្វធ្វើការបន្តពូជខាងក្នុងហើយតែងតែធ្វើការបន្តពូជនៅពេលយប់ នៅតាមវាលដីខ្សាច់ ឬភក់ច្រាំងទន្លេ អូរ ឬអាងទឹកដែលវារស់នៅ។ នៅក្នុងរដូវវស្សា ជាពិសេស ពេលមានភ្លៀងធ្លាក់ខ្លាំង កន្ធាយញីនឹងចាប់ផ្តើមទំលាក់ពងភ្លាមៗតែម្តង រួចជើងមុខទាំងពីររបស់វាកាយដីខ្សាច់លប់គ្របជិតពីលើពងរយៈពេលពី ៥០-៦០ថ្ងៃ រហូតដល់ពេលញាស់ជាកូន។





*កន្ធាយទម្លាក់ពង*

កំលាំងបន្តពូជរបស់កន្ធាយញី អាស្រ័យលើប្រភេទ និងទម្ងន់នីមួយៗ ដោយឡែកចំពោះកន្ធាយផ្កាដែលមានទម្ងន់៥០០ក្រាម/ក្បាល អាចទំលាក់ពងបានចន្លោះពី ៤-៦គ្រាប់ពងក្នុងមួយដង និងពី៨-១៥គ្រាប់ពងក្នុងមួយដង ករណីកន្ធាយញីទម្ងន់ ១-១.៥គ.ក្រ/ក្បាល ហើយអាចទំលាក់ពងបានចំនួនពី២-៥ដងក្នុងមួយឆ្នាំ ករណីល័ក្ខខ័ណ្ឌសីតុណ្ហភាពសមស្របចន្លោះពី២៥-៣២ អង្សាសេ។ ពងនីមួយៗអាចមានទម្ងន់ពី ៤-៧ក្រាម/គ្រាប់ពង និងអង្កត់ផ្ចិតគ្រាប់ពងពី ២០-២៣ ម.ម។ ចំពោះប្រភេទកន្ធាយផ្សេងៗទៀត ដូចជាកន្ធាយបន្លា ដែលមានទម្ងន់៤-៤.៥គ.ក្រ/ក្បាល អាចទំលាក់ពង

បានចន្លោះពី ២០-៣០គ្រាប់ពងក្នុងមួយដង ហើយអាចទំលាក់ពងបានចំនួនពី២-៥ ដងក្នុងមួយឆ្នាំ។

## IV. បច្ចេកទេសចិញ្ចឹមកន្ធាយ

### ១. ប្រភពទឹកសម្រាប់ចិញ្ចឹមកន្ធាយ

ប្រភព និងគុណភាពទឹកសម្រាប់ចិញ្ចឹមកន្ធាយ គឺជាកត្តាសំខាន់ នៅក្នុងការរស់នៅ លូតលាស់ និងធំធាត់។ ជាការពិតណាស់ ទឹកយកមកពីប្រភពណា ក៏អាចចិញ្ចឹមកន្ធាយបានដែរ តែអ្វីដែលសំខាន់នោះគឺទឹកត្រូវមានគុណភាពល្អ ពោលគឺគ្មានភាពកខ្វក់ ជូ ឬជាតិអាស៊ីតខ្ពស់ ភ្លាវ។ល។ ប្រភពទឹកសំខាន់ៗ អាចចិញ្ចឹមកន្ធាយបានល្អ និងទទួលបាននូវទិន្នផលខ្ពស់ រួមមានដូចជាៈ ទឹកទន្លេ បឹងបួរ ស្រះស្តុកទឹកធម្មជាតិ ទឹកប្រឡាយ ។ល។ កត្តាគុណភាពទឹកសំខាន់គឺ នៅក្នុងដំណើរការចិញ្ចឹម ចាំបាច់យើងត្រូវតែមានការត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពឱ្យបានល្អជាប់ជាប្រចាំដោយធ្វើយ៉ាងណា ឱ្យទឹកមានចលនាជានិច្ច ដោយប្រើកង្ហារវាយទឹក ឬប្រើឧបករណ៍បញ្ចូលអុកស៊ីហ្សែនបន្ថែម ដើម្បីជៀសវាងការខ្វះបរិមាណអុកស៊ីហ្សែនរលាយក្នុងទឹកស្រះ ដែលអាចបណ្តាលឱ្យកន្ធាយមានជំងឺ ឬការធំធាត់ លូតលាស់យឺត។




*ការធ្វើឱ្យស្រះចិញ្ចឹមកន្ធាយមានអុកស៊ីសែន*

### ២. ការជ្រើសរើសកូនពូជដាក់ចិញ្ចឹម

គុណភាពកូនពូជគឺជាកត្តាសំខាន់ នៅក្នុងការចិញ្ចឹមកន្ធាយ ក៏ដូចជាការចិញ្ចឹមត្រី និងវារិសត្វផ្សេងៗទៀតផងដែរ ដើម្បីទទួលបានជោគជ័យ និងទិន្នផលខ្ពស់។

អាស្រ័យហេតុនេះ យើងត្រូវធ្វើការជ្រើសរើសគុណភាពកូនពូជដាក់ចិញ្ចឹមទៅតាមគោលការណ៍បច្ចេកទេសណែនាំដូចខាងក្រោម៖

- កូនពូជដែលមានសុខភាពល្អ គ្មានស្នាមរបួស និងបាត់បង់នូវសារពាង្គកាយណាមួយ
- កូនពូជមានប្រភពច្បាស់លាស់ ពោលគឺមកពីកសិដ្ឋានផលិតកូនដែលមានការអនុញ្ញាត់ និងច្បាប់ត្រឹមត្រូវ
- កូនពូជមានទម្ងន់១០០ក្រាមក្នុងមួយក្បាល ហើយមានទំហំប៉ុនៗគ្នាល្អសម្រាប់ដាក់ចិញ្ចឹម ជៀសវាងការខាំ ឬស៊ីគ្នា
- គួរជ្រើសរើសកូនពូជកន្ធាយមកដាក់ចិញ្ចឹមនៅចន្លោះខែកុម្ភៈដល់ឧសភា ព្រោះក្នុងអំឡុងពេលនេះ ជាពេលវេលាដ៏សមស្របបំផុត
- ជ្រើសរើសកូនពូជកន្ធាយដែលមានគុណភាពល្អ មកដាក់ចិញ្ចឹមក្នុងស្រះបន្ទាប់ពីបានរក្សាវានៅក្នុងស្បៃសំណាញ់រយៈពេលមួយសប្តាហ៍ជាមុនសិនដោយចាប់យកចេញនូវកូនពូជណាដែលមានគុណភាពមិនល្អចេញ។




ការជ្រើសរើសកូនពូជកន្ធាយសម្រាប់ដាក់ចិញ្ចឹម

### ៣. ការរៀបចំស្រះចិញ្ចឹមកន្ធាយ

ស្រះចិញ្ចឹមកន្ធាយគួររៀបចំឱ្យមានរាងចតុកោណកែង ហើយមានទំហំចាប់ពី ១០០ ម៉ែត្រការេឡើង ដែលមាន ជម្រៅចន្លោះពី ១ -១,៥ ម៉ែត្រ។ ស្រះគួរមានទីតាំង

នៅជិតផ្ទះ នៅទីកន្លែងស្ងប់ស្ងាត់ មិនមានមនុស្សដើរឆ្លងកាត់ច្រើនដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការគ្រប់គ្រង មើលថែទាំផ្តល់ចំណី និងការផ្លាស់ប្តូរទឹកថ្មីម្តងៗ។




ស្រះ ចិញ្ចឹមកន្ធាយនៅខេត្តសៀមរាប

បន្ទាប់ពីរៀបចំស្រះរួច បញ្ចូលទឹកជម្រៅ ៣តឹក ហើយនៅជុំវិញលើខ្នងភ្លឺស្រះ ត្រូវធ្វើរបងសំណាញ់ ឬ ស័ង្កសី ព័ទ្ធជុំវិញ កម្ពស់ ១ម៉ែត្រ ដើម្បីការពារកន្ធាយវារចេញទៅក្រៅស្រះ។ ក្រៅពីនេះ យើងត្រូវរៀបចំជម្រកដល់កន្ធាយសម្រាប់ជ្រក និងជាម្លប់ផងដែរ ដោយមានដាំដំណាំដើមឈើហូបផ្លែនៅតាមមាត់ស្រះ និងដាំត្រកួន កំប្លោក កញ្ឆែតនៅក្នុងទឹកស្រះ ព្រមទាំងរៀបចំជម្រកបន្ថែមពីក្តារបន្ទះ ឬដើមឫស្សីឱ្យមានលក្ខណៈជម្រេលបន្តិច ងាយស្រួលដល់កន្ធាយអាចវារឡើងហាលពន្លឺថ្ងៃបាន។ នៅបាតស្រះ ត្រូវរក្សាកម្រាស់ភក់ជម្រៅពី ១០ - ២០ ស.ម និង បញ្ចូលទឹកជម្រៅពី




ការដាំដំណាំជុំវិញស្រះ និងដំណាំលើទឹកជាជម្រក

០.៨-១ម៉ែត្រ បន្ទាប់មកបាចកំបោរស ប្រមាណ ១ គីឡូក្រាមក្នុង១០០ម៉ែត្រការ៉េស្រះ រួចហាលថ្ងៃរយៈពេល ២សប្តាហ៍ មុនពេលលែងកូនកន្ធាយចូលស្រះចិញ្ចឹម។

### ៨. ដង់ស៊ីតេកូនកន្ធាយដាក់ចិញ្ចឹម

ដង់ស៊ីតេ ក៏ជាកត្តាកំណត់ និងសំខាន់ផងដែរ នៅក្នុងការចិញ្ចឹមកន្ធាយឱ្យទទួលបានជោគជ័យ និងទិន្នផលខ្ពស់។ ដង់ស៊ីតេ ឬចំនួនកូនកន្ធាយដាក់ចិញ្ចឹមនៅក្នុងមួយម៉ែត្រការ៉េស្រះ អាស្រ័យលើដំណាក់កាលវិវត្ត លូតលាស់ ធំធាត់នីមួយៗ ពោលគឺទំហំ និងទម្ងន់កូនកន្ធាយបានវិវត្តនៅក្នុងដំណាក់កាលនីមួយៗដូចខាងក្រោម៖

- កូនកន្ធាយ បន្ទាប់ពីភ្ញាស់បានរយៈពេល២ខែ ដែលមានទម្ងន់ចន្លោះពី ១០-១៥ក្រាម/ក្បាលយើងអាចដាក់វាចិញ្ចឹមបានក្នុងកម្រិតដង់ស៊ីតេចន្លោះពី១០-១៥ ក្បាល/ម២
- កម្រិតដង់ស៊ីតេចន្លោះពី ៥-១០ក្បាល/ម២ ស្រះ ដំណាក់កាលកូនកន្ធាយ មានទម្ងន់ចន្លោះពី ១០០-២០០ក្រាម/ក្បាល
- កម្រិតដង់ស៊ីតេចន្លោះពី៣-៥ក្បាល/ម២ ស្រះ ដំណាក់កាលកូនកន្ធាយ មានទម្ងន់ ៥០០ក្រាម/ក្បាល។




### ការជ្រើសរើសកូនកន្ធាយពូជសម្រាប់ដាក់ចូលក្នុងស្រះចិញ្ចឹម

កូនកន្ធាយ មុនពេលលែងចូលស្រះចិញ្ចឹម ត្រូវធ្វើអនាម័យ សម្អាត កំចាត់ចោលនូវរាល់មេរោគផ្សេងៗតោងជាប់លើដងខ្លួនកូនកន្ធាយដោយប្រើល្បាយសូលុយស្យុងសូដ្យូមក្លរួ ១០% ឬសូលុយស្យុងពែរម៉ង់កាណាត បរិមាណ ១មីលីក្រាម/លីត្រ

ទឹករយៈពេល ១០នាទី មុនពេលលែងចូលស្រះចិញ្ចឹម។




កូនកន្ធាយក្រោយពេលសម្អាត

### ៨. ចំណី និងការផ្តល់ចំណី

ប្រភេទចំណីសំខាន់ៗសម្រាប់ចិញ្ចឹមកន្ធាយ រួមមានបីប្រភេទគឺ (១) ប្រភេទចំណីស្រស់ (២)ប្រភេទចំណីផ្សំ និង(៣)ប្រភេទចំណីគ្រាប់។ ចំណីទាំងបីប្រភេទនោះ មានបកស្រាយលម្អិតដូចខាងក្រោម៖

☞ ប្រភេទចំណីស្រស់: ជាប្រភេទចំណី ដែលប្រជាកសិករអាចរកបាននៅតាមមូលដ្ឋាន ភូមិ ឃុំរបស់ពួកគាត់ រួមមាន: ប្រភពធនធានចំណី បានមកពីសមុទ្រ ដូចជា ត្រីជី កូនត្រីល្អិត និងកាកសំណល់ខ្យង ក្តាម។ល។ និងប្រភេទចំណីបានមកពីប្រភពទឹកសាបដូចជា កំពឹស ក្តាម ខ្យង សត្វល្អិត ជន្លេន និងកាកសំណល់ពីផ្ទះបាយ រោងចក្រ កាកសំណល់សត្តឃាតដ្ឋាន ។ល។



ខ្យងសម្រាប់ផ្សំចំណី



កាកសំណល់សត្តឃាតដ្ឋាន

☞ ប្រភេទចំណីផ្សំ: ជាប្រភេទចំណី ដែលប្រជាកសិករអាចរកបាននៅតាមមូលដ្ឋាន ភូមិ ឃុំរបស់ពួកគាត់ រួមមាន: កន្ទក់ ចុងអង្គ ដំឡូងផ្វា ម្សៅសណ្តែកសៀង ពោត សណ្តែកសៀង និងម៉្យាត្រី។ល។ ដោយលាយបញ្ចូលគ្នា រួចចម្អិនឱ្យឆ្អិនមុនពេលឱ្យកន្ធាយស៊ី។ ប្រភេទចំណីផ្សំខាងលើ មុនពេលផ្តល់ឱ្យកន្ធាយស៊ី គួរលាយបន្ថែមជាមួយម្សៅវីតាមីនព្រីមិច និងសារធាតុជួយរំលាយអាហារ ដើម្បីជួយដល់ការការពារបង្កាជំងឺផ្សេងៗនិងការលូតលាស់លឿន។









*ចំណីផ្សំសម្រាប់ផ្តល់ឱ្យកន្ធាយ*

☞ ប្រភេទចំណីគ្រាប់: ជាប្រភេទចំណីផលិតចេញពីរោងចក្រ មានសមាសធាតុផ្សំចំណីគ្រប់គ្រាន់ តាមតម្រូវការ និងកម្រិតប្រូតេអ៊ីនខ្ពស់អាចធ្វើឱ្យកន្ធាយធំធាត់លឿន។ ប៉ុន្តែ ចំណីគ្រាប់ក៏ជាប្រភេទចំណីមានតម្លៃខ្ពស់លើទីផ្សារ ជាពិសេសទីផ្សារក្នុងប្រទេសកម្ពុជាយើងដោយប្រភេទចំណីនេះ ត្រូវនាំចូលពីប្រទេសជិតខាង។



ចំណីជាកូនត្រី និងត្រាប់រុក្ខជាតិ



ចំណី ត្រាប់ចេញពីរោងចក្រ

ដោយឡែក ចំពោះចំណីផ្សំ ត្រូវធានាឱ្យបាននូវគុណភាព ជៀសវាងមានពពួកបាក់តេរីផ្សេងៗ ផ្សិម ដុះផ្សិត និង ចំពោះចំណីស្រស់ ត្រូវចិញ្ច្រាំឱ្យម៉ដ្ឋ ល្អិត ដោយដៃ ឬម៉ាស៊ីនកិន រួចចម្អិនឱ្យឆ្អិនល្អ មុនពេលឱ្យកន្ធាយស៊ីដើម្បី ជៀសវាងការប៉ះពាល់មិនល្អដល់ប្រព័ន្ធរំលាយអាហារ ជាពិសេស នៅក្នុងដំណាក់កាលកូនកន្ធាយទើបលែងចូលស្រះចិញ្ចឹមដំបូង។ ចំណីផ្សំទាំងនេះ ត្រូវផ្តល់ឱ្យកន្ធាយស៊ីនូវបរិមាណសមស្របបានកំណត់ នៅតាមមាត់ស្រះនៃជ្រុងនីមួយៗ តែត្រូវជៀសវាងបោះចំណីចូលស្រះដោយផ្ទាល់ដែលអាចបណ្តាលឱ្យគុណភាពទឹកស្រះឆាប់កខ្វក់ ស្អុយ ខូចគុណភាព។ បរិមាណចំណីត្រូវផ្តល់ឱ្យកន្ធាយស៊ី ប្រមាណ ៥-៨%ធៀបទម្ងន់ដងខ្លួនសរុប ពេលអាកាសធាតុត្រជាក់ល្អសមស្រប ដែលមានកម្រិតសីតុណ្ហភាពចន្លោះពី ២៥-២៩°C



ការផ្តល់ចំណីឱ្យកន្ធាយ

និងពេលអាកាសធាតុត្រជាក់ជាងនេះ មានកម្រិតចន្លោះពី ២០-២៥អង្សាសេ បរិមាណចំណី ត្រូវបានកាត់បន្ថយចន្លោះពី ៤-៥% ធៀបទម្ងន់ដងខ្លួនសរុប ចំនួន២-៣ដងនៅក្នុងមួយថ្ងៃ នៅពេលមេឃត្រជាក់ល្អ ជាពិសេស ពេលព្រឹក និងរសៀលត្រជាក់។ ជាទូទៅ ដើម្បីចិញ្ចឹមកន្ធាយបាន១គីឡូក្រាមសាច់ យើងត្រូវចំណាយចំណីអស់ប្រមាណ

ពី១៧ ទៅ១៨ គ.ក្រ។

ប៉ុន្តែ នៅក្នុងដំណាក់កាលដំបូង ពេលទើបលែងកូនកន្ធាយចូលស្រះចិញ្ចឹម យើងគួរស្ងោរជំឡូងផ្វាឱ្យឆ្អិនមានលក្ខណៈទន់ជ្រាយ ផុយល្មម រួចកិនឱ្យបែកម៉ដ្ឋតូចៗ មុនពេលផ្តល់ឱ្យកូនកន្ធាយស៊ីនៅលើបន្ទះក្តារ បានរៀបចំតាមមាត់ស្រះនៃជ្រុងស្រះនីមួយៗនូវបរិមាណដូចបានរៀបរាប់ខាងលើ។ បន្ទាប់ពីចិញ្ចឹមបានរយៈពេល ១ខែ យើងអាចចិញ្ច្រាំជំឡូងផ្វាឆៅល្អិតៗផ្តល់ឱ្យកូនកន្ធាយស៊ីជំនួសវិញបាន រហូតដល់រយៈពេល៣ខែ ទើបយើងអាចផ្តល់ឱ្យកន្ធាយស៊ីនូវប្រភេទចំណីស្រស់ធម្មតាវិញបាន ដូចជាពពួក កំពិស ត្រីល្អិត ជន្លេន លាស ក្តាម និងកង្កែប ឬផ្លែឈើ និងគ្រាប់ធញ្ញជាតិ




ការផ្តល់ជាចំណីជន្លេនក្រហាមសម្រាប់កន្ធាយ

ផ្សេងៗ ចំណីផ្សំដូចជា កន្ទក់ ចុងអង្ក ពោត សណ្តែកសៀង និងម្សៅត្រី។ល។ នូវបរិមាណពី ៥-៨%នៃទម្ងន់ខ្លួនសរុប ចំនួនពី២-៣ដងក្នុង១ថ្ងៃ។

### ៦. ការគ្រប់គ្រងស្រះ

នៅក្នុងអំឡុងពេល ចិញ្ចឹមកន្ធាយ ត្រូវឧស្សាហ៍ ព្យាយាម តាមដាន ត្រួតពិនិត្យជាប្រចាំដើម្បីការពារទំនប់ភ្លឺស្រះរបងស្បៃព័ទ្ធជុំវិញកុំឱ្យដាច់ធ្លុះធ្លាយអាចបណ្តាលឱ្យកូនកន្ធាយចេញទៅក្រៅស្រះបាន។ ត្រូវធ្វើការផ្លាស់ប្តូរ ទឹកស្រះជាប្រចាំ និងទៀងទាត់ពេលវេលាកំណត់ និងជាក់ស្តែង ដែលជាគោលការណ៍បច្ចេកទេសតម្រូវឱ្យយើងត្រូវធ្វើការផ្លាស់ប្តូរទឹកថ្មីនូវរៀងរាល់មួយសប្តាហ៍ម្តង ឬក្នុងករណី សង្កេតឃើញថាទឹកមានពណ៌បៃតងចាស់ កម្រិតថ្លានៃទឹកតូចជាង៣០ស.ម ឬ៣តឹក (<៣០ស.ម)





ការផ្លាស់ប្តូរទឹកស្រះចិញ្ចឹមកន្ទាយ

ដែលអាចបណ្តាលឱ្យខ្វះបរិមាណអុកស៊ីហ្សែនរលាយក្នុងទឹកស្រះ និងកន្ទាយវារឡើងចេញទឹកស្រះ។ គួរធ្វើការផ្លាស់ប្តូរទឹកថ្មី នូវបរិមាណចន្លោះពី ២០-៥០% នៃបរិមាណទឹកសរុបក្នុងស្រះនៅរៀងរាល់មួយសប្តាហ៍ម្តង និង ពីរសប្តាហ៍ម្តង នូវបរិមាណចន្លោះពី៥០ -១០០% អាស្រ័យលើស្ថានភាពគុណភាពទឹកស្រះជាក់ស្តែង ។

គួរបញ្ចៀសឱ្យបាននូវការបង្កឡើងដោយសម្លេង ឮខ្លាំងៗដែលជាបញ្ហាដល់ការស់នៅ លូតលាស់ ធំធាត់ ក៏ដូចជាការភ័យខ្លាចរបស់កន្ទាយ។ ចំពោះការផ្តល់ចំណីត្រូវធ្វើឡើងទៅតាមគោលការណ៍បច្ចេកទេស បានណែនាំខាងលើ ពោលគឺត្រូវផ្តល់ចំណីដល់កន្ទាយ នៅលើក្តារបន្ទះ បានរៀបចំតាមមាត់ស្រះនៃជ្រុងស្រះនីមួយៗនូវ





បន្ទះស៊ីម៉ង់ចងនៅមាត់ស្រះសម្រាប់ដាក់ចំណី

បរិមាណពី៥-៨%ធៀបទម្ងន់ដងខ្លួនសរុប ពេលអាកាសធាតុត្រជាក់ល្អសមស្រប និងពេលអាកាសធាតុក្តៅ គួរបន្ថយនូវបរិមាណចន្លោះពី ២-៣% ធៀបទម្ងន់ដងខ្លួនសរុប ចំនួន២-៣ដងនៅក្នុងមួយថ្ងៃ នៅពេលមេឃត្រជាក់ ជាពិសេស ពេលព្រឹក និងរសៀលត្រជាក់។ ប៉ុន្តែ ត្រូវជៀសវាងការផ្តល់ចំណីលើស សល់ច្រើនធ្លាក់ចូលបាតស្រះបណ្តាលឱ្យឆាប់ខូចគុណភាពទឹកស្រះ និងបង្កឱ្យកន្ធាយងាយនឹងកើតជំងឺផ្សេងៗដូចជាធ្វើឱ្យមានការលូតលាស់យឺត។

បន្ទាប់ពីចិញ្ចឹមបានរយៈពេល ៦ខែ ចាំបាច់ ត្រូវចាប់វាញែកចេញពីគ្នារវាងញី និងឈ្មោល ទៅដាក់ចិញ្ចឹមក្នុងស្រះពីរផ្សេងពីគ្នា ព្រោះថា កន្ធាយនៅក្នុងដំណាក់កាលនេះ មានទំហំកាន់តែធំ ដែលជាមធ្យមមានទម្ងន់ប្រមាណ ៥០០ក្រាមក្នុងមួយក្បាល ធ្វើឱ្យទីធ្លាចិញ្ចឹមកាន់តែចង្អៀត និងជាពិសេស វាអាចនឹងខាំគ្នាបង្កស្នាម របួស ដំបៅ និងបង្កជំងឺផ្សេងៗ ឬអាចស៊ីគ្នាតែម្តង ពេលខ្វះចំណី។

### ៧. ជំងឺ និងការបង្ការជំងឺ

តាមរយៈបទពិសោធន៍ចិញ្ចឹម និងការអង្កេតកន្លងមក ឃើញថា ករណីចិញ្ចឹមកន្ធាយតាមបែបលក្ខណៈគ្រួសារក្នុងស្រះដី ដោយដាក់ចិញ្ចឹមកម្រិតដង់ស៊ីតេទាបចន្លោះពី ៣-៥ក្បាល/ម$^{2}$ ស្រះ និងមានការគ្រប់គ្រងគុណភាពទឹកបានល្អ នោះកម្រនឹងជួបបញ្ហាជំងឺផ្សេងៗកើតឡើងណាស់ បើធៀបនឹងការចិញ្ចឹម តាមបែបលក្ខណៈពាណិជ្ជកម្ម ក្នុងប្រព័ន្ធអាងស៊ីម៉ង់ត៍ដោយដាក់ចិញ្ចឹមនូវកម្រិតដង់ស៊ីតេខ្ពស់ និងការគ្រប់គ្រងមិនបានល្អតាមគោលការណ៍បច្ចេកទេសបានណែនាំ ដែលអាចបណ្តាលឱ្យកើតមានឡើងនូវជំងឺផ្សេងៗជាច្រើន និងអាចឆ្លងរាលដាលគ្នាយ៉ាងឆាប់រហ័សពីមួយទៅមួយផ្សេងទៀតនៅក្នុងអាងចិញ្ចឹមតែមួយដូចគ្នា។ ដើម្បីបង្ការបាននូវជំងឺផ្សេងៗអាចកើតមានឡើងចំពោះកន្ធាយចិញ្ចឹម ជាពិសេស ការចិញ្ចឹមតាមបែបលក្ខណៈពាណិជ្ជកម្ម នោះត្រូវអនុវត្តធ្វើតាមវិធានការ ការពារមួយចំនួនដូចខាងក្រោម៖

**ការផ្លាស់ប្តូរទឹកថ្មី:** ត្រូវធ្វើការផ្លាស់ប្តូរទឹកថ្មីជាប្រចាំ នូវបរិមាណចន្លោះពី ២០-៥០% នៃបរិមាណទឹកសរុបក្នុងស្រះនៅរៀងរាល់មួយសប្តាហ៍ម្តង និង នៅរៀងរាល់

ពីរសប្តាហ៍ម្តង នូវបរិមាណចន្លោះពី៥០ -១០០% អាស្រ័យលើស្ថានភាពគុណភាពទឹកស្រះជាក់ស្តែង ។

ការរៀបចំស្រះមុនពេលដាក់កូនកន្ធាយចិញ្ចឹមៈ ត្រូវរៀបចំសម្អាតស្រះឡើងវិញឱ្យបានស្អាត ល្អនៅរៀងរាល់ក្រោយប្រមូលផលរួច និងមុនពេលដាក់កូនកន្ធាយចិញ្ចឹមវគ្គបន្ទាប់។ ការរៀបចំស្រះ ត្រូវ ប្រើកំបោរនូវបរិមាណចន្លោះពី១០-១៥ គ.ក្រ ក្នុង១០០ម$^2$ ស្រះ ដើម្បីសម្អាត និងសម្លាប់ឱ្យអស់នូវរាល់ពពួកមេរោគផ្សេងៗដែលអាចបង្កជំងឺបានដល់កន្ធាយ។

ប្រភេទជំងឺតែងជួបប្រទះ : កន្លងមក ជំងឺតែងតែជួបប្រទះ កើតមានឡើងលើកន្ធាយចិញ្ចឹមតាមបែបលក្ខណពាណិជ្ជកម្ម គឺជំងឺហើមករ។



*សត្វកន្ធាយមានជំងឺហើមក*

វិធីព្យាបាលៈ ករណីជួបប្រទះនឹងជំងឺហើមករ ឃើញថា កន្ធាយ មិនអាចស៊ីចំណីបានទេ។ ដូច្នេះ យើងអាច ព្យាបាលវាបាន ដោយប្រើប្រភេទថ្នាំ Clorocid/Sulfamid លាយជាមួយចំណី រួចដាក់ឱ្យកន្ធាយស៊ី នៅថ្ងៃដំបូង នូវកម្រិត ០,២ក្រាមក្នុង១គ.ក្រចំណី ចំនួន២ថ្ងៃជាប់គ្នា និងបន្ទាប់ពីនេះ បន្ថយបរិមាណប្រើ នូវកម្រិត ០,១ក្រាម/គ.ក្រ ចំណីប៉ុណ្ណោះ ដោយលាយជាមួយចំណីដាក់ឱ្យកន្ធាយស៊ី រយៈពេល៣ថ្ងៃបន្តទៀត។




ការដាក់ថ្នាំលាយជាមួយចំណីឱ្យកន្ធាយស៊ី

**ប្រភេទជំងឺផ្សិតៈ** ជាប្រភេទជំងឺសើរស្បែក តែងតែកើតមានឡើងនៅលើករ និងជើងរបស់វា មានលក្ខណៈពណ៌សរ ដែលអាចបណ្តាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងអាចងាប់បាន នូវអត្រាខ្ពស់ ប្រមាណ ៤០% ។




កន្ធាយមានជំងឺផ្សិត

**វិធីព្យាបាលៈ** ប្រភេទជំងឺផ្សិតនេះ យើងអាចព្យាបាលវាបាន ដោយប្រើប្រភេទថ្នាំគ្រាប់ឈ្មោះ TCCA 90% នូវបរិមាណ ១ក្រាម /ម$^{៣}$ ទឹកស្រះ (ថ្នាំគ្រាប់ TCCA 90% Clorine ផលិតផលប្រទេសជប៉ុន ចិន ជួយបង្កើនក្លរក្នុងទឹក) ដោយបាចចូលទៅក្នុងទឹកទឹកស្រះចិញ្ចឹមកន្ធាយ។ ជំងឺប្រភេទនេះតែងតែកើតមានឡើង ជាញឹកញាប់ណាស់ ជាពិសេស ពេលអាកាសធាតុត្រជាក់ និងក្នុងរដូវមានភ្លៀងធ្លាក់ នូវកម្រិតសីតុណ្ហភាពចន្លោះពី ១៨-២៥ អង្សាសេ ។

**ប្រភេទជំងឺរលាកបង្កដោយបាក់តេរីៈ** ជំងឺប្រភេទនេះ តែងតែបង្កឡើងដោយ






ការប្រើថ្នាំ TCCA 90% Clorine ទៅក្នុងទឹកស្រះដើម្បីព្យាបាល

លក្ខខ័ណ្ឌស្រះចិញ្ចឹមចង្អៀត ពេលគឺកម្រិតបរិមាណ ឬដង់ស៊ីតេកន្ធាយដាក់ចិញ្ចឹមខ្ពស់ ហួសពីលក្ខណៈបច្ចេកទេសបានកំណត់ ហើយបង្កឱ្យខូចគុណភាពទឹកស្រះ មានលក្ខណៈកខ្វក់ មានក្លិនស្អុយ និងខ្វះបរិមាណអុកស៊ីហ្សែនរលាយក្នុងទឹក។ ពេលប្រភេទជំងឺនេះកើតឡើង យើងតែងសង្កេតឃើញ កន្ធាយ មានរលាកនៅលើក្បាល ករ មាត់ និងជើងរបស់វា។ ករណី មានការរលាកធ្ងន់ធ្ងរ អាចបង្កឱ្យមានជាខ្ទុះឈាម រីកម្រាមជើង ភ្នែកក្រហម និងកំលាំងចុះខ្សោយ មិនសូវស៊ីចំណី ហើយអាចងាប់បាន ករណីការព្យាបាលមិនបានទាន់ពេលវេលា។





ជំងឺរលាកបង្កដោយបាក់តេរីលើកន្ធាយ

វិធីព្យាបាលៈ ជំងឺប្រភេទនេះ យើងអាចព្យាបាលបាន ដោយប្រើថ្នាំព្យាបាល លាយជាមួយខ្លាញ់ជ្រូក លាបលើកន្លែងដែលមានស្នាមរបួសរលាក ហើយរក្សាវាទុក

នៅលើគោករយៈពេលពី ៣០-៦០ នាទី ដើម្បីឱ្យថ្នាំស្ងួតអស់ រួចទើបអាចលែងចូលទឹកស្រះចិញ្ចឹមវិញ។ ការព្យាបាលដោយរបៀបនេះ ត្រូវបានធ្វើឡើង នៅក្នុងរយៈពេលចំនួន ៧ថ្ងៃជាប់គ្នា។ ជាទូទៅ គេសង្កេតឃើញថា ជំងឺប្រភេទនេះ តែងតែកើតមានឡើងតែចំពោះ ការចិញ្ចឹមតាមបែបលក្ខណៈពាណិជ្ជកម្មប៉ុណ្ណោះ។



ការលាបថ្នាំលើកន្លែងរលាក

## ៨.ការប្រមូលផល

ជាទូទៅ កសិករតែងតែធ្វើការប្រមូលផល បន្ទាប់ពីចិញ្ចឹមបានរយៈពេលចន្លោះពី ១២-១៦ខែ ដែលពេលនេះ កន្ធាយមានទម្ងន់ចន្លោះពី១-១,៥គីឡូក្រាម ក្នុងមួយក្បាល ឬអាចលើសពីនេះ។ ការប្រមូលផល តែងតែត្រូវបានធ្វើឡើងនៅចន្លោះពីខែវិច្ឆិកា និងខែធ្នូ ដែលជារដូវអាកាសធាតុត្រជាក់ និងកន្ធាយមិនសូវស៊ីចំណី អាចបង្កឡើងបាននូវប្រភេទជំងឺផ្សេងៗ។ វិធីសាស្រ្តក្នុងការប្រមូលផល ជាដំបូង យើងត្រូវបង្ហូរទឹកចេញពីក្នុងស្រះដោយសន្សឹមៗ និងដោយប្រោះនឹងក្រឡាសំណាញ់ ដើម្បីរក្សាទុកកន្ធាយមានទំហំធំ អាចយកទៅលក់លើទីផ្សារបាន។ ចំពោះកូនកន្ធាយដែលមានទំហំតូច តែមានសុខភាពល្អ កំលាំងខ្លាំង រហ័សរហួនត្រូវ រក្សាទុកសម្រាប់ចិញ្ចឹមបន្តទៀត។

ការប្រមូលផលសរុប នៅដំណាក់កាលចុងក្រោយ គឺត្រូវបានធ្វើឡើងដោយប្រើសំណាញ់ ចាប់បន្ទាប់ពីបង្ហូរទឹកចេញអស់ពីស្រះ។ កន្ធាយនីមួយៗ ត្រូវបានគេចាប់ដាក់ក្នុងថង់ប្លាស្ទិក ឬកសំណាញ់ដែលមានក្រឡាទំហំពី ៣-៤ ម.ម ហើយបន្ទាប់មកទៀត យកវាទៅដាក់ក្នុងបាវ ធុង ឬប្រអប់ធុងស្នោរ និងរក្សាឱ្យមានសំណើមជានិច្ច។ ការចាប់កន្ធាយ ត្រូវបានធ្វើឡើងដោយខណៈថ្នមៗ មានការប្រុងប្រយ័ត្នខ្ពស់ដើម្បីជៀសវាងការបង្កឱ្យមានរបួសស្នាមដល់កន្ធាយ៕





ការប្រមូលផលកន្ធាយ







សត្វកន្ធាយកំពុងមានទីផ្សារល្អក្នុងពេលបច្ចុប្បន្ន

# ឯកសារយោង៖


1. FAO: http://www.fao.org/fishery/culturedspecies/Trionyx_sinensis/en

2. https://khomay3a.com (Ky thuat noui BA BA huong dan Tu A-Z )

3. https://www.rfi.fr/km/cambodia/kratie-rfi-oudom-21-06-2017

4. Email: info@hanteco.vn>clori-vie https://hoa-chatdaiviet.com

5. Cach su dung lieu loung TCCA 90% dung nhat hien nay 14 ខែ 01 ឆ្នាំ 2020 By HOA TUY

6. https://vi.m.wikipedia.org> Ho Ba ba-Wikipedia tieng Viet

7. www.rasmeinews.com ( កន្ធាយក្បាលកង្កែបនៅកម្ពុជា ប្រភពក្រសួងបរិស្ថាន jul 31,2017)





